# ផែនការសម្អាតកម្អួតនិងលាមករាក

**Do it Right! Serve it Safe!**

## ព័ត៌មានគ្រឹះស្ថាន

- **ឈ្មោះ** ______________________________
- **អាសយដ្ឋាន** ______________________________

## ផែនការសម្អាត

### អតិថិជន

- ☐ យកមនុស្សចេញឱ្យឆ្ងាយ
- ☐ រាំងខ្ទប់ក្នុងចម្ងាយ 25 ហ្វីតនៅជុំវិញកន្លែងដែលមានមេរោគ។ កុំឱ្យមនុស្សចូល។
- ☐ ផ្សេងៗ៖ ______________________________

### ផ្ទៃខាងលើ

- ☐ ប្រើប្រាស់សម្ភារៈដែលប្រើហើយអាចបោះចោលបានដូចជា ម្សៅ baking soda ឬដីខ្សាច់ដែលសម្រាប់អោយឆ្មាបតជើង (kitty litter) ដើម្បីស្រូបយកកម្អួតនិងលាមករាក។ កើបវាដាក់ចូលទៅក្នុងធុងសំរាមហើយបោះវាចោល។
- ☐ ប្រើទឹកសាប៊ូដើម្បីសម្អាតផ្ទៃខាងលើ។
- ☐ រំងាប់មេរោគនៅតាមលើផ្ទៃក្នុងកន្លែងនោះ។ ប្រើទឹកថ្នាំរំងាប់មេរោគដើម្បីសម្លាប់មេរោគវីរុសនានា។ នេះគឺជាផលិតផលមួយផ្សេងខុសពីទឹកថ្នាំសម្លាប់មេរោគក្នុងផ្ទះបាយ។ អនុវត្តតាមការណែនាំនៅលើស្លាកផលិតផល។
- ☐ យកសម្ភារៈសម្អាតទាំងអស់ដែលអាចបោះចោលបានក្រោយពេលប្រើរួច បោះចោលក្នុងថង់សំរាម។ នេះរាប់បញ្ចូលទាំងគ្រឿងសម្ភារៈដូចជា ស្លាបព្រា ក្បាលប្រដាប់ជូតឥដ្ឋ ស្រោមដៃ និងកន្សែង។ បោះចោលថង់សំរាមទៅក្នុងធុងសំរាមធំនៅខាងក្រៅជាបន្ទាន់។
- ☐ សម្អាត និងរំងាប់មេរោគតាមគ្រឿងបរិក្ខារដែលអាចប្រើឡើងវិញបាននៅក្នុងឡាបូប្រដាប់ជូតឥដ្ឋ។
- ☐ បោះចោលសារធាតុរំងាប់មេរោគដែលប្រើរួច។
- ☐ ផ្សេងៗ៖ ______________________________

### អាហារនិងភេសជ្ជ

- ☐ មិនត្រូវរៀបចំចាត់ចែងចំណីអាហារឬភេសជ្ជៈនៅកន្លែងនោះទេ។
- ☐ យកអាហារដែលមិនបានគ្រប ឬរបស់របរដែលសម្រាប់យកមកប្រើបានតែម្ដង ដែលស្ថិតនៅក្នុងកន្លែងនោះ ទៅបោះចោល។
- ☐ លាងសម្អាតរាល់គ្រឿងប្រើប្រាស់ និងគ្រឿងបរិក្ខារដែលស្ថិតនៅក្នុងកន្លែងនោះ។
- ☐ ផ្សេងៗ៖ ______________________________

### បុគ្គលិក

- ☐ បញ្ជូនបុគ្គលិកដែលមានជំងឺទាំងអស់ទៅផ្ទះជាបន្ទាន់។ បុគ្គលិកមានជំងឺ មិនអាចត្រឡប់ទៅធ្វើការវិញបានទេ រហូតដល់ពួកគេគ្មានរោគសញ្ញាក្នុងរយៈពេល 24 ម៉ោង។
- ☐ ពាក់ម៉ាស់ ស្រោមស្បែកជើង ស្រោមដៃដែលប្រើហើយអាចបោះចោល និងអៀមការពារដើម្បីលាងសម្អាតកម្អួតនិងលាមករាក។
- ☐ លាងដៃភ្លាមៗនៅក្នុងឡាបូលាងដៃក្នុងបន្ទប់ទឹក បន្ទាប់ពីសម្អាតរួច។
- ☐ បញ្ជូនរាល់បុគ្គលិកទាំងឡាយណាដែលបានជួយសម្អាតទៅផ្ទះ។ ពួកគេគួរតែងូតទឹក និងផ្លាស់ប្ដូរសម្លៀកបំពាក់។
- ☐ បុគ្គលិកត្រូវតែរាយការណ៍ពីរោគសញ្ញាក្អួតឬរាករូស ទៅកាន់អ្នកគ្រប់គ្រងរបស់ពួកគេបន្ទាប់ពីសម្អាតរួច។
- ☐ ផ្សេងៗ៖ ______________________________

## ការចាត់តាំងបុគ្គលិក

ចាត់តាំងបុគ្គលិកក្រៅពីផ្នែកចំណីអាហារឱ្យបំពេញភារកិច្ចសម្អាត បើអាចធ្វើបាន។

▶ **តើគួរជូនដំណឹងទៅនរណា ប្រសិនបើកើតមានហេតុការណ៍ក្អួតឬរាករូស?**

☐ អ្នកគ្រប់គ្រង ☐ អ្នកសម្អាត ☐ អ្នកបម្រើអាហារ ☐ ផ្សេងៗ

▶ **តើនរណាជាអ្នកទទួលខុសត្រូវខាងសម្អាតកម្អួតនិងលាមករាក?**

☐ អ្នកគ្រប់គ្រង ☐ អ្នកសម្អាត ☐ អ្នកបម្រើអាហារ ☐ ផ្សេងៗ

## កញ្ចប់សម្ភារៈសម្អាត

▶ **ឈុតសម្ភារៈសម្អាតរបស់អ្នកគួរតែមាន៖**

- ម៉ាស់ប្រើហើយអាចបោះចោលបាន
- ស្រោមដៃប្រើហើយអាចបោះចោលបាន
- អៀមប្រើហើយអាចបោះចោលបាន
- វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ
- វត្ថុធាតុស្រូបទឹក ដូចជាម្សៅស្ងួត ឬខ្សាច់ដែលប្រើសម្រាប់អោយឆ្មាបតជើង។
- ប្រដាប់ចូកដែលអាចបោះចោលក្រោយពេលប្រើរួច។
- ថង់សំរាម
- ក្រដាសជូតដៃ
- ក្បាលប្រដាប់ជូតឥដ្ឋប្រើហើយអាចបោះចោលបាន
- ធុងប្រដាប់ជូតឥដ្ឋ
- ស្លាកបាំងឬស្លាកសញ្ញាហាមកុំអោយមនុស្សឆ្លងកាត់។
- ស្រោមស្បែកជើង
- សារធាតុរំងាប់មេរោគ
- ផ្សេងៗ៖ ____________________

▶ **ទីតាំងផ្ទុកកញ្ចប់សម្ភារៈសម្អាត** ________________________________________

**!** ឧបករណ៍ដែលប្រើដើម្បីសម្អាតកម្អួតនិងលាមករាកមិនគួររក្សាទុកឬយកទៅសម្អាតនៅក្នុងផ្ទះបាយទេ។ សម្អាតឧបករណ៍ដែលអាចប្រើឡើងវិញបាននៅក្នុងឡាបូប្រដាប់ជូតឥដ្ឋ។

## ការបណ្ដុះបណ្ដាលបុគ្គលិក

បុគ្គលិកត្រូវតែទទួលបានការបណ្ដុះបណ្ដាលអោយបានត្រឹមត្រូវជាមុន។ រក្សាកំណត់ត្រាថាបុគ្គលិកណាខ្លះបានទទួលការបណ្ដុះបណ្ដាល និងនៅពេលណា។

▶ **តើបុគ្គលិកទទួលបានការបណ្ដុះបណ្ដាលដូចម្ដេច?**

☐ អានផែនការ ☐ ការបង្ហាញអំពីរបៀបប្រើប្រាស់កញ្ចប់សម្ភារៈសម្អាត ☐ ផ្សេងៗ

▶ **បុគ្គលិកត្រូវបានទទួលការបណ្ដុះបណ្ដាលនៅពេលជួលមកធ្វើការ ហើយនិង៖**

☐ ប្រចាំត្រីមាស ☐ ប្រចាំឆ្នាំ ☐ ផ្សេងៗ

## កំណត់ចំណាំបន្ថែម